**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ២៥៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការគ្រប់គ្រង និងលើកកម្ពស់ប្រសិទ្ធភាពថាមពលនៃបរិក្ខារប្រើប្រាស់អគ្គិសនី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃ២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកម្ភៈឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១៥/០០៥ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល។

# សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់បទប្បញ្ញត្តិសម្រាប់គ្រប់គ្រង និងលើកកម្ពស់ប្រសិទ្ធភាពថាមពលនៃបរិក្ខារប្រើប្រាស់អគ្គិសនីក្នុងព្រះរាជាណាចក្រកម្ពុជា តាមរយៈការអនុវត្តបទដ្ឋាននិងការបិទស្លាកសញ្ញាប្រសិទ្ធភាពថាមពលស្របតាមគោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល។

**មាត្រា២ .-**

អនុក្រឹត្យនេះ មានវិសាលភាពគ្របដណ្តប់លើរាល់សកម្មភាពនៃការបញ្ញត្តិ ការគ្រប់គ្រង ការទទួលខុសត្រូវរបស់ស្ថាប័នរាជរដ្ឋាភិបាល និងការលើកកម្ពស់ប្រសិទ្ធភាពថាមពលនៃបរិក្ខារប្រើប្រាស់អគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

គោលការណ៍នៃប្រសិទ្ធភាពថាមពល គឺជាក់លាក់ចំពោះ "បរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញា" នីមួយៗ ដូច្នេះ វិសាលភាពបទដ្ឋានគុណផលនិងសុវត្ថិភាព វិធីសាស្ត្រធ្វើតេស្ត បទដ្ឋានគុណផលប្រើប្រាស់ថាមពលអប្បបរមា កម្រិតប្រសិទ្ធភាពថាមពល ការរចនាស្លាកប្រសិទ្ធភាពថាមពល នីតិវិធីត្រួតពិនិត្យនិងផ្ទៀងផ្ទាត់ ត្រូវរៀបចំនិងដាក់ឱ្យអនុវត្តសម្រាប់បរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញានីមួយៗ ហើយបំពេញបន្ថែមតាមតម្រូវការ ដោយមានការណែនាំលម្អិត និងនីតិវិធីប្រតិបត្តិការស្តង់ដាជាក់លាក់។

អនុក្រឹត្យនេះកំណត់តួនាទី និងការទទួលខុសត្រូវរបស់ស្ថាប័នរាជរដ្ឋាភិបាលផ្សេងៗគ្នា ក្នុងការគ្រប់គ្រង និងលើកកម្ពស់ប្រសិទ្ធភាពថាមពលនៃបរិក្ខារប្រើប្រាស់អគ្គិសនី។

**មាត្រា៣ .-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងអនុក្រឹត្យនេះ មាននិយមន័យដូចខាងក្រោម៖

**បរិក្ខារប្រើប្រាស់អគ្គិសនី** សំដៅដល់ឧបករណ៍ ឬគ្រឿងប្រដាប់ប្រដាសម្រាប់ប្រើប្រាស់ ឬគ្រឿងម៉ាស៊ីន ឬសម្ភារៈទាំងឡាយណាដែលប្រើប្រាស់ថាមពលអគ្គិសនីសម្រាប់ធ្វើការងារ និងបំពេញតម្រូវការរបស់អ្នកប្រើប្រាស់។

**បរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញា** សំដៅដល់បរិក្ខារប្រើប្រាស់អគ្គិសនីទាំងឡាយណា ដែលស្ថាប័នបង្គោលចេញលិខិតបទដ្ឋានគតិយុត្តកំណត់ថាជាបរិក្ខារមុខសញ្ញាដែលត្រូវធ្វើការគ្រប់គ្រង និងលើកកម្ពស់ប្រសិទ្ធភាពថាមពល តាមបទប្បញ្ញត្តិនៃបទដ្ឋាននិងការបិទស្លាកសញ្ញាប្រសិទ្ធភាពថាមពល។

**ស្លាកសញ្ញាប្រសិទ្ធភាពថាមពល** សំដៅដល់ស្លាកសញ្ញាព័ត៌មានដែលចេញដោយស្ថាប័នបង្គោលពណ៌នាអំពីគុណផលការប្រើប្រាស់ថាមពល កម្រិតប្រសិទ្ធភាពថាមពលនៃបរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញានោះ និងព័ត៌មានលម្អិតសំខាន់ៗផ្សេងទៀត។ ស្លាកសញ្ញាទាំងនេះត្រូវបិទនៅលើបរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញា។

**កម្រិតប្រសិទ្ធភាពថាមពល** សំដៅដល់កម្រិតនៃប្រសិទ្ធភាពថាមពលខ្ពស់ឬទាបរបស់បរិក្ខារប្រើប្រាស់អគ្គិសនី។ កម្រិតប្រសិទ្ធភាពថាមពលរបស់បរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញា ត្រូវមានបង្ហាញនៅលើស្លាកសញ្ញាប្រសិទ្ធភាពថាមពល បិទលើបរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញានោះ។

**ម៉ូដែល** សំដៅដល់ម៉ូដែលមួយ ឬចង្កោមម៉ូដែលនៃម៉ាកជាក់លាក់មួយ ដែលអាចយកសំណុំនៃរបាយការណ៍ធ្វើតេស្តតែមួយទៅអនុវត្តបាន ហើយម៉ូដែលនីមួយៗមានលក្ខណៈរូបវន្ត ការប្រើប្រាស់ថាមពល ប្រសិទ្ធភាពថាមពល និងលក្ខណៈគុណផលដូចគ្នា។

**បទដ្ឋានគុណផលការប្រើប្រាស់ថាមពលអប្បបរមា** សំដៅដល់លក្ខខណ្ឌគុណផលនៃការប្រើប្រាស់ថាមពលកម្រិតតិចបំផុត ដែលបរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញាត្រូវបំពេញឱ្យបាន មុននឹងអនុញ្ញាតឱ្យផលិត នាំចូល និងដាក់លក់បរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញានេះបាន។

**ស្ថាប័នបង្គោល** សំដៅដល់ស្ថាប័នរាជរដ្ឋាភិបាល ដែលទទួលខុសត្រូវដឹកនាំរួមការអនុវត្តបទប្បញ្ញត្តិនៃបទដ្ឋាននិងការបិទស្លាកសញ្ញាប្រសិទ្ធភាពថាមពល ដែលកំណត់ក្នុងអនុក្រឹត្យនេះ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

**ស្ថាប័នដៃគូ** សំដៅដល់អង្គភាព ឬស្ថាប័នរាជរដ្ឋាភិបាលនានា ដែលគាំទ្រស្ថាប័នបង្គោលក្នុងការអនុវត្តបទប្បញ្ញត្តិនៃបទដ្ឋាននិងការបិទស្លាកសញ្ញាប្រសិទ្ធភាពថាមពល ដែលកំណត់ក្នុងអនុក្រឹត្យនេះ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

**បទប្បញ្ញត្តិនៃបទដ្ឋាននិងការបិទស្លាកសញ្ញាប្រសិទ្ធភាពថាមពល** សំដៅដល់បទប្បញ្ញត្តិទាំងឡាយក្នុងអនុក្រឹត្យនេះ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ក្នុងគោលបំណងធ្វើការគ្រប់គ្រង និងលើកកម្ពស់ប្រសិទ្ធភាពថាមពលនៃបរិក្ខារប្រើប្រាស់អគ្គិសនីក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២
## ស្ថាប័នទទួលខុសត្រូវ

**មាត្រា៤ ..**

ក្រសួងរ៉ែនិងថាមពលជាស្ថាប័នបង្គោលដែលទទួលខុសត្រូវរួមលើការងារគ្រប់គ្រងនិងលើកកម្ពស់ប្រសិទ្ធភាពថាមពលនៃបរិក្ខារប្រើប្រាស់អគ្គិសនី ដោយមានតួនាទី និងភារកិច្ចទទួលខុសត្រូវ ដូចខាងក្រោម៖

១- គ្រប់គ្រង និងលើកកម្ពស់ប្រសិទ្ធភាពថាមពលនៃបរិក្ខារប្រើប្រាស់អគ្គិសនី ដោយសហការជាមួយស្ថាប័នដៃគូស្របតាមតួនាទី ការទទួលខុសត្រូវ និងនីតិវិធី ដែលមានចែងក្នុងអនុក្រឹត្យនេះ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

២- ពិនិត្យ កែសម្រួល និងធ្វើបច្ចុប្បន្នភាព បញ្ជីបរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញា ដែលត្រូវធ្វើការគ្រប់គ្រង និងលើកកម្ពស់ប្រសិទ្ធភាពថាមពល។

៣- កំណត់បទដ្ឋានគុណផលការប្រើប្រាស់ថាមពលអប្បបរមា និងគោលការណ៍វាយតម្លៃកម្រិតប្រសិទ្ធភាពថាមពលនៃបរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញា។

៤- រៀបចំប្រកាស នីតិវិធី គោលការណ៍ណែនាំ សំណុំឧបករណ៍ និងមធ្យោបាយផ្សព្វផ្សាយផ្សេងៗសម្រាប់ការអនុវត្តបទប្បញ្ញត្តិនៃបទដ្ឋាននិងការបិទស្លាកសញ្ញាប្រសិទ្ធភាពថាមពល។

៥- ដាក់ចេញនូវការរចនាស្លាកសញ្ញាប្រសិទ្ធភាពថាមពល និងសេចក្ដីណែនាំអំពីការប្រើប្រាស់ស្លាកសញ្ញាប្រសិទ្ធភាពថាមពលនេះ។

៦- រៀបចំសេចក្ដីណែនាំ និងនីតិវិធីប្រតិបត្តិការស្តង់ដាជាក់លាក់សម្រាប់អ្នកស្នើសុំ និងស្ថាប័នដៃគូ ហើយជូនដំណឹងអំពីគោលការណ៍ណែនាំ និងនីតិវិធីប្រតិបត្តិការស្តង់ដាតាមរយៈប្រកាស។

៧- ត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងពង្រឹងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ ដើម្បីធានាថា ការផលិត និងការលក់បរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញាក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវតែមានការអនុលោមតាមបទប្បញ្ញត្តិនៃបទដ្ឋាននិងការបិទស្លាកសញ្ញាប្រសិទ្ធភាពថាមពល។

៨- ផ្ដល់ការយល់ព្រម ឬបដិសេធ ការចុះបញ្ជីទទួលស្គាល់បរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញា។

៩- ធានាអនុវត្តផែនការត្រួតពិនិត្យ និងវាយតម្លៃប្រសិទ្ធភាពថាមពលនៃបរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញាក្នុងព្រះរាជាណាចក្រកម្ពុជា។

១០-ផាកពិន័យ និងដោះស្រាយបណ្ដឹងតវ៉ា ពាក់ព័ន្ធនឹងអនុលោមភាពនៃបរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញាក្នុងក្របខណ្ឌបទប្បញ្ញត្តិនៃបទដ្ឋាននិងការបិទស្លាកសញ្ញាប្រសិទ្ធភាពថាមពល។

**មាត្រា៥ ..**

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ជាស្ថាប័នដៃគូទទួលខុសត្រូវជួយដល់ក្រសួងរ៉ែ និងថាមពល ក្នុងការកំណត់ស្តង់ដានៃការធ្វើតេស្តដែលត្រូវអនុវត្តចំពោះបរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញា និង លក្ខខណ្ឌវិនិច្ឆ័យសម្រាប់ការទទួលស្គាល់មន្ទីរពិសោធន៍ធ្វើតេស្ត ព្រមទាំងក្នុងការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងពង្រឹង ការអនុវត្តវិធានការច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធដើម្បីធានាថា ការផលិតបរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញាក្នុង គោលបំណងធ្វើពាណិជ្ជកម្មក្នុងព្រះរាជាណាចក្រកម្ពុជា អនុលោមទៅតាមបទប្បញ្ញត្តិនៃបទដ្ឋាននិងការបិទស្លាក សញ្ញាប្រសិទ្ធភាពថាមពល។ តួនាទី និងភារកិច្ចទទួលខុសត្រូវរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ មានដូចខាងក្រោម៖

១- ផ្តល់អនុសាសន៍លើស្តង់ដានៃការធ្វើតេស្តដែលត្រូវអនុវត្តចំពោះបរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញា តាម សំណើរបស់ក្រសួងរ៉ែនិងថាមពល។

២- ត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងពង្រឹងការអនុវត្តវិធានការច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ ដើម្បីធានាថាការផលិត បរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញាក្នុងគោលបំណងធ្វើពាណិជ្ជកម្មក្នុងព្រះរាជាណាចក្រកម្ពុជា អនុលោម តាមបទប្បញ្ញត្តិនៃបទដ្ឋាន និងការបិទស្លាកសញ្ញាប្រសិទ្ធភាពថាមពល។

៣- ហាមឃាត់ការផលិតម៉ូដែលនៃបរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញាទាំងឡាយណា ដែលមិនអនុលោមតាម បទប្បញ្ញត្តិនៃបទដ្ឋាននិងការបិទស្លាកសញ្ញាប្រសិទ្ធភាពថាមពល។

៤- ផាកពិន័យចំពោះអ្នកផលិតបរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញា ដែលមិនអនុលោមតាមបទប្បញ្ញត្តិនៃបទដ្ឋាន និងការបិទស្លាកសញ្ញាប្រសិទ្ធភាពថាមពល។

៥- កំណត់លក្ខខណ្ឌវិនិច្ឆ័យសម្រាប់ការទទួលស្គាល់មន្ទីរពិសោធន៍ធ្វើតេស្តបរិក្ខារប្រើប្រាស់អគ្គិសនីក្នុងគោល-បំណងផ្ទៀងផ្ទាត់អនុលោមភាពនៃបរិក្ខារប្រើប្រាស់អគ្គិសនី ជាមួយបទដ្ឋានប្រសិទ្ធភាពថាមពល។

៦- កត់ត្រា និងផ្តល់ព័ត៌មានជាប្រចាំដល់ក្រសួងរ៉ែនិងថាមពល អំពីការត្រួតពិនិត្យដែលបានធ្វើ និងការផាកពិន័យ ដែលបានអនុវត្តដោយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**មាត្រា៦ ..**

ក្រសួងពាណិជ្ជកម្មជាស្ថាប័នដៃគូទទួលខុសត្រូវជួយដល់ក្រសួងរ៉ែនិងថាមពល ក្នុងការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងពង្រឹងការអនុវត្តវិធានការច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធដើម្បីធានាថា ការដាក់លក់បរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញា នៅក្នុងទីផ្សារនៃព្រះរាជាណាចក្រកម្ពុជា អនុលោមទៅតាមបទប្បញ្ញត្តិនៃបទដ្ឋាននិងការបិទស្លាកសញ្ញាប្រសិទ្ធភាព ថាមពល។ តួនាទី និងភារកិច្ចទទួលខុសត្រូវរបស់ក្រសួងពាណិជ្ជកម្មមានដូចខាងក្រោម៖

១- ហាមឃាត់ការលក់ម៉ូដែលនៃបរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញាទាំងឡាយណា ដែលក្រសួងរ៉ែនិងថាមពល បានផ្តល់ព័ត៌មានថា មិនអនុលោមទៅតាមបទប្បញ្ញត្តិនៃបទដ្ឋាននិងការបិទស្លាកសញ្ញាប្រសិទ្ធភាពថាមពល។

២- ហាមឃាត់ការលក់បរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញាទាំងឡាយណាដែលមិនមានបិទស្លាកសញ្ញាប្រសិទ្ធភាពថាមពលចេញដោយក្រសួងរ៉ែនិងថាមពល។

៣- ផាកពិន័យចំពោះអ្នកលក់បរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញាណា ដែលមិនមានបិទស្លាកសញ្ញាប្រសិទ្ធភាពថាមពលចេញដោយក្រសួងរ៉ែនិងថាមពល ឬបិទស្លាកសញ្ញាប្រសិទ្ធភាពថាមពលដែលខុសពីការកំណត់ ឬក្លែងក្លាយ ស្របទៅតាមបទប្បញ្ញត្តិនៃបទដ្ឋាននិងការបិទស្លាកសញ្ញាប្រសិទ្ធភាពថាមពល។

៤- កត់ត្រា និងផ្តល់ព័ត៌មានជាប្រចាំដល់ក្រសួងរ៉ែនិងថាមពល អំពីការត្រួតពិនិត្យដែលបានធ្វើ និងការផាកពិន័យដែលបានអនុវត្តដោយក្រសួងពាណិជ្ជកម្ម។

**មាត្រា៧ .-**

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាជាស្ថាប័នដែលទទួលខុសត្រូវជួយដល់ក្រសួងរ៉ែនិងថាមពលក្នុងការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងពង្រឹងការអនុវត្តវិធានការច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធដើម្បីធានាថា ការនាំចូលបរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញាមកក្នុងព្រះរាជាណាចក្រកម្ពុជា អនុលោមទៅតាមបទប្បញ្ញត្តិនៃបទដ្ឋាននិងការបិទស្លាកសញ្ញាប្រសិទ្ធភាពថាមពល។ តួនាទី និងភារកិច្ចទទួលខុសត្រូវរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា មានដូចខាងក្រោម៖

១- ត្រូវពិនិត្យលទ្ធភាពនៃការចាត់វិធានការដោយឈរលើគោលការណ៍រក្សាបានតុល្យភាពកិច្ចសម្រួលពាណិជ្ជកម្ម និងការធានាអនុលោមភាព។

២- អនុញ្ញាតឱ្យធ្វើការនាំចូលដើម្បីលក់ចែកចាយក្នុងព្រះរាជាណាចក្រកម្ពុជា ចំពោះតែរូបវន្តបុគ្គលឬនីតិបុគ្គលណាដែលបានចុះបញ្ជីបរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញារួចនៅក្រសួងរ៉ែនិងថាមពល។

៣- សហការជាមួយក្រសួងរ៉ែនិងថាមពល និងភាគីពាក់ព័ន្ធតាមការស្នើសុំ ដើម្បីចុះពិនិត្យ អនុលោមភាពចំពោះបរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញាទាំងឡាយណាដែលសង្ស័យថាមិនអនុលោមតាមបញ្ញត្តិនៃអនុក្រឹត្យនេះ ដែលកំពុងរក្សាទុក លក់ និងចែកចាយក្នុងព្រះរាជាណាចក្រកម្ពុជា។

៤- ចាប់ឃាត់ ដកហូត និងផាកពិន័យចំពោះអ្នកនាំចូលម៉ូដែលបរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញាណា ដែលមិនអនុលោមតាមបទប្បញ្ញត្តិនៃបទដ្ឋាននិងការបិទស្លាកសញ្ញាប្រសិទ្ធភាពថាមពល ព្រមទាំងកំណត់ជាក្រុមហ៊ុនដែលមានហានិភ័យខ្ពស់។

៥- សហការផ្លាស់ប្តូរបច្ចុប្បន្នភាពទិន្នន័យការចុះបញ្ជី ការផលិត និងការនាំចូលនូវបរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញាជាមួយក្រសួងរ៉ែនិងថាមពល និងត្រូវមានមន្ត្រីទំនាក់ទំនង។

## ជំពូកទី៣
## ការកំណត់បរិក្ខារប្រើប្រាស់អគ្គិសនីជាបរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញា និង គោលការណ៍ប្រសិទ្ធភាពថាមពលនៃបរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញា

**មាត្រា៨ .-**

ក្រសួងរ៉ែនិងថាមពល ត្រូវកំណត់បរិក្ខារប្រើប្រាស់អគ្គិសនីជាក់លាក់ណាមួយជាបរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញា ដោយប្រកាសអន្តរក្រសួងរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងរ៉ែនិងថាមពល។

១. បទប្បញ្ញត្តិប្រសិទ្ធភាពថាមពលនៃបរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញាត្រូវអនុលោមតាមបទប្បញ្ញត្តិនៃបទដ្ឋាន និងការបិទស្លាកសញ្ញាប្រសិទ្ធភាពថាមពលដូចដែលបានកំណត់ក្នុងអនុក្រឹត្យនេះ និងប្រកាសពាក់ព័ន្ធរបស់ក្រសួងរ៉ែនិងថាមពល។

២. គោលការណ៍នៃប្រសិទ្ធភាពថាមពលគឺមានភាពជាក់លាក់ចំពោះបរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញានីមួយៗ ហើយត្រូវកំណត់ដោយប្រកាសសម្រាប់បរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញានោះដែលចេញដោយក្រសួងរ៉ែនិងថាមពល។ វិសាលភាព បទដ្ឋានគុណផល និងសុវត្ថិភាព វិធីសាស្ត្រធ្វើតេស្ត បទដ្ឋានគុណផលប្រើប្រាស់ថាមពលអប្បបរមា កម្រិតប្រសិទ្ធភាពថាមពល ការរចនាស្លាកប្រសិទ្ធភាពថាមពល និងនីតិវិធីត្រួតពិនិត្យត្រូវកំណត់សម្រាប់បរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញានីមួយៗ។

៣. ក្រសួងរ៉ែនិងថាមពលក៏ត្រូវបង្កើតគោលការណ៍ណែនាំជាក់លាក់ និងនីតិវិធីប្រតិបត្តិការស្តង់ដាសម្រាប់អ្នកស្នើសុំ និងស្ថាប័នដៃគូ ហើយជូនដំណឹងអំពីគោលការណ៍ណែនាំ និងនីតិវិធីប្រតិបត្តិការស្តង់ដាតាមរយៈប្រកាសរបស់ក្រសួងរ៉ែនិងថាមពល។

## ជំពូកទី៤
## នីតិវិធីចុះបញ្ជីនិងបិទស្លាកសញ្ញាប្រសិទ្ធភាពថាមពល
## នៃបរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញា

**មាត្រា៩ .-**

អ្នកនាំចូល ឬក្រុមហ៊ុនផលិត ជារូបវន្តបុគ្គល ឬនីតិបុគ្គលត្រូវចុះបញ្ជីបរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញាជាមួយក្រសួងរ៉ែនិងថាមពល ដើម្បីទទួលបានស្លាកប្រសិទ្ធភាពថាមពល មុនពេលនាំចូល ឬផលិតសម្រាប់លក់ក្នុងព្រះរាជាណាចក្រកម្ពុជា។ បរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញាដែលត្រូវផលិត នាំចូល និងលក់នៅលើទីផ្សារនៃព្រះរាជាណាចក្រកម្ពុជា ត្រូវមានស្លាកសញ្ញាប្រសិទ្ធភាពថាមពល ដែលចេញដោយក្រសួងរ៉ែនិងថាមពល។

**មាត្រា១០ .-**

នីតិវិធីសម្រាប់ការដាក់ពាក្យស្នើសុំ ការវាយតម្លៃកម្រិតប្រសិទ្ធភាពថាមពល របាយការណ៍ធ្វើតេស្តបរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញា តម្រូវការសម្រាប់ការទទួលស្គាល់មន្ទីរពិសោធន៍ និងការបង់ថ្លៃសេវាជាដើម ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងរ៉ែនិងថាមពល។

**មាត្រា១១ .-**

ក្រសួងរ៉ែនិងថាមពលត្រូវពិនិត្យនិងវាយតម្លៃលើពាក្យស្នើសុំរបស់អ្នកស្នើសុំ និងលើម៉ូដែលបរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញាដែលបានស្នើសុំ តាមការកំណត់ក្នុងមាត្រា ១០ និងត្រូវសម្រេចថាតើត្រូវយល់ព្រមចុះបញ្ជីនិងផ្តល់ស្លាកសញ្ញាប្រសិទ្ធភាពថាមពលសម្រាប់ម៉ូដែលដែលបានស្នើសុំនោះដែរឬទេ។

ប្រសិនបើការវាយតម្លៃប្រសិទ្ធភាពថាមពលរបស់ម៉ូដែលនៃបរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញាដែលបានស្នើសុំនោះបង្ហាញថា ម៉ូដែលនៃបរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញានោះអនុលោមតាមបទប្បញ្ញត្តិនៃបទដ្ឋាននិងការបិទស្លាកសញ្ញាដែលកំណត់ដោយអនុក្រឹត្យនេះ និងប្រកាសពាក់ព័ន្ធ ក្រសួងរ៉ែនិងថាមពលត្រូវចុះបញ្ជីម៉ូដែលនៃបរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញា និងចេញស្លាកសញ្ញាប្រសិទ្ធភាពថាមពលឱ្យអ្នកស្នើសុំ តាមកម្រិតប្រសិទ្ធភាពថាមពលនៃម៉ូដែលបរិក្ខារប្រើប្រាស់អគ្គិសនីដែលបានស្នើសុំនោះ។

ក្នុងករណី ការវាយតម្លៃប្រសិទ្ធភាពថាមពលនៃម៉ូដែលបរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញាដែលបានស្នើសុំបង្ហាញថា ម៉ូដែលបរិក្ខារប្រើប្រាស់អគ្គិសនីនេះ មិនអនុលោមតាមបទប្បញ្ញត្តិនៃបទដ្ឋាននិងការបិទស្លាកសញ្ញាកំណត់ដោយអនុក្រឹត្យនេះ និងប្រកាសពាក់ព័ន្ធ ក្រសួងរ៉ែនិងថាមពលត្រូវចេញលិខិតបដិសេធការស្នើសុំស្លាកសញ្ញាប្រសិទ្ធភាពថាមពលនៃបរិក្ខារប្រើប្រាស់អគ្គិសនីដែលស្នើសុំនេះ ដោយមានការបញ្ជាក់ច្បាស់លាស់អំពីមូលហេតុនៃការបដិសេធ។

បន្ទាប់ពីធ្វើការសម្រេចរួច ក្រសួងរ៉ែនិងថាមពលត្រូវជូនដំណឹងដល់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្រសួងពាណិជ្ជកម្ម និងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាអំពីការសម្រេចស្តីពីការចុះបញ្ជីនិងការផ្តល់ស្លាកសញ្ញាប្រសិទ្ធភាពថាមពល នៃបរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញាដែលបានស្នើសុំនេះដើម្បីឱ្យស្ថាប័នដៃគូទាំងនេះមានចំណាត់ការស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

អ្នកស្នើសុំស្លាកសញ្ញាប្រសិទ្ធភាពថាមពលសម្រាប់បរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញាណាមួយ ដើម្បីបិទលើផលិតផលដែលត្រូវផលិត ឬនាំចូល ដើម្បីដាក់លក់លើទីផ្សារនៃព្រះរាជាណាចក្រកម្ពុជា ត្រូវដាក់ពាក្យស្នើសុំចុះបញ្ជីនិងសុំស្លាកសញ្ញាប្រសិទ្ធភាពថាមពលសម្រាប់បរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញានោះ ជាមួយក្រសួងរ៉ែនិងថាមពល។

ក្រសួងរ៉ែនិងថាមពល ត្រូវរៀបចំនិងដាក់ឱ្យអនុវត្តនូវសេចក្តីណែនាំស្តីពីដំណើរការនៃការដាក់ពាក្យស្នើសុំតម្រូវការព័ត៌មាន ការវាយតម្លៃកម្រិតប្រសិទ្ធភាពថាមពល ការថែរក្សាសំណៅនៃសំណាកបរិក្ខារដែលបានស្នើសុំ វិវេចនារបាយការណ៍ធ្វើតេស្តគុណផលនៃសំណាកបរិក្ខារប្រើប្រាស់អគ្គិសនី តម្រូវការការវាយតម្លៃទទួលស្គាល់មន្ទីរពិសោធន៍ និងការបង់ថ្លៃសេវាផ្សេងៗរបស់អ្នកស្នើសុំ។

**មាត្រា១២ .-**

រាល់បរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញា ត្រូវតែមានបិទស្លាកសញ្ញាប្រសិទ្ធភាពថាមពលមុនពេលដាក់លក់

នៅលើទីផ្សារក្នុងព្រះរាជាណាចក្រកម្ពុជា។ ស្លាកសញ្ញាប្រសិទ្ធភាពថាមពល មានកម្រិតប្រសិទ្ធភាពថាមពល ៥កម្រិត។ កម្រិត១ ជាកម្រិតទាបបំផុត និងកម្រិត៥ ជាកម្រិតប្រសិទ្ធភាពខ្ពស់បំផុត។ ស្លាកសញ្ញាប្រសិទ្ធភាពថាមពល ត្រូវផ្តល់នូវព័ត៌មានមួយចំនួន ដូចជាកម្រិតប្រសិទ្ធភាពថាមពល ប្រភេទបរិក្ខារប្រើប្រាស់អគ្គិសនី លេខម៉ូដែល លក្ខណៈបច្ចេកទេសសំខាន់ៗ ស្តង់ដាធ្វើតេស្តយោង ប៉ារ៉ាម៉ែត្រប្រសិទ្ធភាពថាមពល និងតម្លៃរបស់វា រួមជាមួយនឹងព័ត៌មានចាំបាច់ផ្សេងទៀត ដែលកំណត់ថាមានការចាំបាច់ដោយប្រកាសរបស់ក្រសួងរ៉ែនិងថាមពល សម្រាប់បរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញាដាក់លាក់នោះ។

ចំពោះព័ត៌មានលម្អិតអំពីទំហំស្លាក ការរចនា សម្ភារៈ និងរបៀបនៃការបិទបង្ហាញ ត្រូវកំណត់នៅក្នុងប្រកាសរបស់ក្រសួងរ៉ែនិងថាមពលសម្រាប់បរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញានីមួយៗ។

**មាត្រា១៣ .-**

ក្រសួងរ៉ែនិងថាមពលត្រូវជូនដំណឹងអំពីការផុតកំណត់ ការពន្យារបន្ត ឬការកែប្រែស្លាកសញ្ញាប្រសិទ្ធភាពថាមពលនៅកំឡុងពេលដាក់លាក់ណាមួយ តាមការយល់ឃើញថាសមរម្យដោយជូនដំណឹងទៅរូបវន្តបុគ្គល ឬនីតិបុគ្គលដែលពាក់ព័ន្ធ។

ស្លាកសញ្ញាប្រសិទ្ធភាពថាមពលដែលបានដាក់ចេញពីមុន នឹងអស់សុពលភាពបន្ទាប់ពីការជូនដំណឹងអំពីការបន្តស្លាកសញ្ញាប្រសិទ្ធភាពថាមពល ដោយការជូនដំណឹងពីក្រសួងរ៉ែនិងថាមពល ហើយរូបវន្តបុគ្គល ឬនីតិបុគ្គលដែលដាក់ពាក្យស្នើសុំពីមុនត្រូវស្នើសុំស្លាកសញ្ញាប្រសិទ្ធភាពថាមពលជាថ្មីឡើងវិញ។

**មាត្រា១៤ .-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលដាក់ពាក្យស្នើសុំចុះបញ្ជីស្លាកសញ្ញាប្រសិទ្ធភាពថាមពល និងបន្តសុពលភាពស្លាកសញ្ញាប្រសិទ្ធភាពថាមពលសម្រាប់ម៉ូដែលបរិក្ខារប្រើប្រាស់អគ្គិសនីនីមួយៗត្រូវបង់កម្រៃសេវាសាធារណៈ។

បែបបទ និងនីតិវិធីនៃការបង់កម្រៃសេវាសាធារណៈត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៥
## ការលក់បរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញា

**មាត្រា១៥ .-**

គ្រប់បរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញា ដែលដាក់លក់នៅក្នុងទីផ្សារនៃព្រះរាជាណាចក្រកម្ពុជាត្រូវបិទស្លាកសញ្ញាប្រសិទ្ធភាពថាមពល ដើម្បីបង្ហាញឱ្យអ្នកទិញបានដឹងអំពីកម្រិតប្រសិទ្ធភាពថាមពល និងព័ត៌មានលម្អិតផ្សេងទៀតនៃបរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញាទាំងនោះ។

ហាមលក់ចែកចាយនូវបរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញាណាមួយ ដែលមិនមានបិទស្លាកសញ្ញាប្រសិទ្ធភាព

ថាមពលចេញដោយក្រសួងរ៉ែនិងថាមពល។ គ្រប់បរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញាដែលពុំមានបិទស្លាកសញ្ញាប្រសិទ្ធភាពថាមពលត្រូវកំណត់ថា មិនអនុលោមតាមបទប្បញ្ញត្តិនៃបទដ្ឋាននិងការបិទស្លាកសញ្ញាប្រសិទ្ធភាពថាមពលដែលបានកំណត់នៅក្នុងអនុក្រឹត្យនេះ និងប្រកាសពាក់ព័ន្ធ។

**មាត្រា១៦ .-**

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ទទួលខុសត្រូវលើការត្រួតពិនិត្យ ការផ្ទៀងផ្ទាត់ និងការដាក់ឱ្យអនុវត្តបទប្បញ្ញត្តិនៃបទដ្ឋាននិងការបិទស្លាកសញ្ញាប្រសិទ្ធភាពថាមពល សម្រាប់ការផលិតបរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញាដែលត្រូវដាក់លក់នៅក្នុងទីផ្សារនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីធានាថាបរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញាទាំងនោះ ពិតជាបានផលិតអនុលោមតាមបទប្បញ្ញត្តិនៃបទដ្ឋាននិងការបិទស្លាកសញ្ញាកំណត់ដោយអនុក្រឹត្រនេះ និងប្រកាសពាក់ព័ន្ធ។

ក្នុងកំឡុងពេលត្រួតពិនិត្យនិងផ្ទៀងផ្ទាត់ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ អាចអនុវត្តវិធានការហិរញ្ញវត្ថុ និង/ឬ វិធានការមិនមែនហិរញ្ញវត្ថុចំពោះរោងចក្រ ឬផលិតករណាដែលផលិតបរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញាដែលមិនអនុលោមតាមបទប្បញ្ញត្តិនៃបទដ្ឋាននិងការបិទស្លាកសញ្ញា កំណត់ដោយអនុក្រឹត្យនេះ និងប្រកាសពាក់ព័ន្ធ។

បែបបទនិងនីតិវិធីនៃការអនុវត្តវិធានការហិរញ្ញវត្ថុ និង/ឬ វិធានការមិនមែនហិរញ្ញវត្ថុត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងរ៉ែនិងថាមពល និងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**មាត្រា១៧ .-**

ក្រសួងពាណិជ្ជកម្ម ទទួលខុសត្រូវលើការត្រួតពិនិត្យ ការផ្ទៀងផ្ទាត់ និងការដាក់ឱ្យអនុវត្តបទប្បញ្ញត្តិនៃបទដ្ឋាននិងការបិទស្លាកសញ្ញាប្រសិទ្ធភាពថាមពល សម្រាប់ការដាក់លក់បរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញា នៅក្នុងទីផ្សារនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីធានាថា បរិក្ខារអគ្គិសនីមុខសញ្ញាទាំងនោះអនុលោមតាមបទប្បញ្ញត្តិនៃបទដ្ឋាននិងការបិទស្លាកសញ្ញាកំណត់ដោយអនុក្រឹត្រនេះ និងប្រកាសពាក់ព័ន្ធ។

តាមរយៈប្រកាសអន្តរក្រសួងរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងរ៉ែនិងថាមពល និងក្រសួងពាណិជ្ជកម្ម ក្រសួងរ៉ែនិងថាមពល និងក្រសួងពាណិជ្ជកម្ម មានសិទ្ធិចាត់វិធានការហិរញ្ញវត្ថុ និង/ឬ វិធានការមិនមែនហិរញ្ញវត្ថុចំពោះអ្នកលក់រាយ ឬអ្នកលក់បរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញាដែលមិនអនុលោមតាមបទប្បញ្ញត្តិនិងការបិទស្លាកសញ្ញាកំណត់ដោយអនុក្រឹត្យនេះ និងប្រកាសពាក់ព័ន្ធ នៅក្នុងកំឡុងពេលត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងអនុវត្ត។

## ជំពូកទី៦
## ការត្រួតពិនិត្យ ការផ្ទៀងផ្ទាត់ និងការពង្រឹងការដាក់ឱ្យអនុវត្ត

**មាត្រា១៨ .-**

ក្រសួងរ៉ែនិងថាមពល និងស្ថាប័នដៃគូរបស់ខ្លួន អាចធ្វើការអង្កេតមើលបរិក្ខារអគ្គិសនីមុខសញ្ញាដែលមាននៅក្នុងទីផ្សារនៃព្រះរាជាណាចក្រកម្ពុជា ដោយផ្ទៀងផ្ទាត់ស្លាកសញ្ញាប្រសិទ្ធភាពថាមពល និងរៀបចំការធ្វើតេស្តត្រួតពិនិត្យ ដើម្បីពិនិត្យអនុលោមភាពនៃបរិក្ខារទាំងនោះ ដែលកំណត់ដោយអនុក្រឹត្យនេះ និងប្រកាសពាក់ព័ន្ធ។

**មាត្រា១៩ .-**

គោលបំណងនៃការផ្ទៀងផ្ទាត់ស្លាកសញ្ញាប្រសិទ្ធភាពថាមពលរបស់បរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញា គឺដើម្បីពិនិត្យមើលថា តើខ្លឹមសារនៃស្លាកសញ្ញាប្រសិទ្ធភាពថាមពលដែលបិទនៅលើបរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញានីមួយៗត្រូវគ្នានឹងខ្លឹមសារដែលអនុម័តដោយស្ថាប័នបង្គោលដែរឬទេ និងថា តើការបិទស្លាកសញ្ញាប្រសិទ្ធភាពថាមពលត្រូវគ្នានឹងការកំណត់អំពីការបិទស្លាកសញ្ញាប្រសិទ្ធភាពថាមពល ដែលចែងក្នុងប្រកាសពាក់ព័ន្ធរបស់ក្រសួងរ៉ែនិងថាមពលដែរឬទេ។

ការផ្ទៀងផ្ទាត់ស្លាកសញ្ញាប្រសិទ្ធភាពថាមពល ត្រូវធ្វើឡើងដោយស្ថាប័នបង្គោល និងស្ថាប័នដៃគូនៅកន្លែងទីផ្សារ ឃ្លាំងស្តុក រោងចក្រ និងទីតាំងផ្សេងទៀតដែលកំណត់ដោយក្រសួងរ៉ែនិងថាមពល។

**មាត្រា២០ .-**

គោលបំណងនៃការធ្វើតេស្តត្រួតពិនិត្យបរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញា គឺដើម្បីធានាថាប្រសិទ្ធភាពថាមពលរបស់បរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញាដែលដាក់លក់នៅក្នុងទីផ្សារនៃព្រះរាជាណាចក្រកម្ពុជា គឺស្របតាមការអះអាងដែលបានផ្តល់ជូនដោយអ្នកស្នើសុំក្នុងកំឡុងពេលចុះបញ្ជីបរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញានោះ និងត្រូវគ្នាជាមួយនឹងស្លាកសញ្ញាប្រសិទ្ធភាពថាមពលដែលបានបិទនៅលើបរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញានោះដែលចេញដោយក្រសួងរ៉ែនិងថាមពល។

ក្រសួងរ៉ែនិងថាមពល ឬតំណាងដែលមានសមត្ថកិច្ច ត្រូវធ្វើតេស្តត្រួតពិនិត្យសំណាកគំរូបរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញាដែលបានជ្រើសរើសខាងលើ នៅក្នុងមន្ទីរពិសោធន៍ដែលមានការទទួលស្គាល់គុណភាពស្របតាមបទប្បញ្ញត្តិកំណត់ដោយអនុក្រឹត្យនេះ និងប្រកាសពាក់ព័ន្ធ។

**មាត្រា២១ .-**

ក្នុងករណីដែលការធ្វើតេស្តត្រួតពិនិត្យបង្ហាញថា សំណាកគំរូបរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញាណាមួយធ្លាក់ការធ្វើតេស្តត្រួតពិនិត្យ អ្នកស្នើសុំចុះបញ្ជីបរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញានោះ ត្រូវទទួលខុសត្រូវចំពោះការផាកពិន័យ។ ក្រសួងរ៉ែនិងថាមពល អាចសម្រេចអនុវត្តការផាកពិន័យ និងចំណាត់ការណាមួយចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលដែលស្នើសុំចុះបញ្ជីនៃបរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញា ដែលធ្លាក់ការធ្វើតេស្តត្រួតពិនិត្យនេះ។

ក្រសួងរ៉ែនិងថាមពលអាចបោះពុម្ពផ្សាយលទ្ធផលធ្លាក់នៃការធ្វើតេស្តត្រួតពិនិត្យនៃសំណាកគំរូបរិក្ខារប្រើប្រាស់

អគ្គិសនីមុខសញ្ញានោះ ហើយជូនដំណឹងដល់សាធារណជនទូទៅតាមរយៈប្រព័ន្ធផ្សព្វផ្សាយសមស្របណាមួយ។

រូបវន្តបុគ្គលឬនីតិបុគ្គល មិនត្រូវលក់បរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញាណា ដែលសំណាកគំរូនៃបរិក្ខារដែលធ្លាក់ការធ្វើតេស្តត្រួតពិនិត្យ និងត្រូវបានផ្សព្វផ្សាយដោយក្រសួងរ៉ែនិងថាមពលនោះឡើយ។

ក្រសួងរ៉ែនិងថាមពល នឹងជូនដំណឹងដល់គ្រប់ស្ថាប័នដៃគូ អំពីម៉ូដែលនៃបរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញាដែលសំណាកគំរូនៃបរិក្ខារនោះធ្លាក់ការធ្វើតេស្តត្រួតពិនិត្យដើម្បីឱ្យស្ថាប័នដៃគូទាំងនេះជួយសម្របសម្រួលស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

**មាត្រា២២ .-**

ផែនការអធិការកិច្ច ទីតាំងដែលអាចធ្វើអធិការកិច្ច ការជ្រើសរើសសំណាកគំរូនៃបរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញាសម្រាប់ការធ្វើតេស្តត្រួតពិនិត្យ ប្រភេទនៃភាពមិនអនុលោម ទម្រង់ឬគំរូសម្រាប់ផែនការអធិការកិច្ច លិខិតអនុញ្ញាតសម្រាប់មន្ត្រីអធិការកិច្ច របាយការណ៍អធិការកិច្ច និងនីតិវិធីលម្អិតសម្រាប់ការផ្ទៀងផ្ទាត់ស្លាកសញ្ញាប្រសិទ្ធភាពថាមពលត្រូវកំណត់ដោយប្រកាសរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល។

## ជំពូកទី៧
## បណ្តឹងតវ៉ា

**មាត្រា២៣ .-**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលមិនសុខចិត្តចំពោះលទ្ធផលនៃការផ្ទៀងផ្ទាត់ស្លាកសញ្ញាប្រសិទ្ធភាពថាមពល ការធ្វើតេស្តត្រួតពិនិត្យ ឬវិធានការណាមួយ ដូចមានចែងក្នុងអនុក្រឹត្យនេះ អាចប្តឹងតវ៉ាក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃ ទៅក្រសួងរ៉ែនិងថាមពល គិតចាប់ពីថ្ងៃទទួលបានសេចក្តីសម្រេចដាក់ពិន័យ។ រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល ត្រូវសម្រេចលើបណ្តឹងតវ៉ានេះក្នុងរយៈពេល ៤៥ (សែសិបប្រាំ)ថ្ងៃយ៉ាងយូរ គិតចាប់ពីថ្ងៃទទួលពាក្យបណ្តឹង។

ក្នុងករណីរូបវន្តបុគ្គលឬនីតិបុគ្គលនោះមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល បុគ្គលនោះមានសិទ្ធិប្តឹងទៅតុលាការមានសមត្ថកិច្ចក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃយ៉ាងយូរ គិតចាប់ពីទទួលបានសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល។

បណ្តឹងតវ៉ារបស់បុគ្គលដែលទទួលរងនូវវិធានការណាមួយនៅក្នុងអនុក្រឹត្យនេះទៅតុលាការពុំមានអានុភាពផ្អាកការអនុវត្តសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលឡើយ។

## ជំពូកទី៨
## ទណ្ឌកម្ម

**មាត្រា២៤ .-**

ទណ្ឌកម្មនៅក្នុងអនុក្រឹត្យនេះរួមមានការព្រមានជាលាយលក្ខណ៍អក្សរ ការផ្អាកសកម្មភាពអាជីវកម្ម ការដកហូត

ស្លាកប្រសិទ្ធភាពថាមពល ការរើបអូសបរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញាដែលបានកំណត់ថាមិនអនុលោមតាមបទប្បញ្ញត្តិនៃបទដ្ឋាននិងការបិទស្លាកសញ្ញាប្រសិទ្ធភាពថាមពល ការផ្សព្វផ្សាយមិនល្អនៅក្នុងប្រព័ន្ធផ្សព្វផ្សាយ និងការផាកពិន័យជាប្រាក់ដោយស្ថាប័នបង្គោល និងស្ថាប័នដៃគូ។

**មាត្រា២៥ .-**

ក្នុងករណីមិនអនុលោមតាមបទប្បញ្ញត្តិក្នុងអនុក្រឹត្យនេះ ការផាកពិន័យត្រូវកំណត់ដោយប្រកាសអន្តរក្រសួង រវាងក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងផ្សេងទៀត (ប្រសិនបើមាន)។

## ជំពូកទី៩
## អន្តរប្បញ្ញត្តិ

**មាត្រា២៦ .-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលនាំចូល ផលិត និងលក់ចែកចាយបរិក្ខារប្រើប្រាស់អគ្គិសនីដែលត្រូវបានកំណត់ជាបរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញា ត្រូវចុះបញ្ជីនិងបិទស្លាកសញ្ញាប្រសិទ្ធភាពថាមពលចំពោះបរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញារបស់ខ្លួនឱ្យស្របតាមវិធានការប្រសិទ្ធភាពថាមពលដូចមានចែងក្នុងអនុក្រឹត្យនេះឱ្យបានជាស្ថាពរ ក្នុងរយៈពេល ១២(ដប់ពីរ) ខែ ក្រោយពេលប្រកាសស្តីពីការកំណត់បរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញាចូលជាធរមាន។

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលនាំចូល ផលិត និងលក់ចែកចាយបរិក្ខារប្រើប្រាស់អគ្គិសនីដែលត្រូវបានកំណត់ជាបរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញា ត្រូវផ្តល់ព័ត៌មានទាក់ទងនឹងគុណផលនៃបរិក្ខារប្រើប្រាស់អគ្គិសនីរបស់ខ្លួនស្របតាមលក្ខខណ្ឌដែលកំណត់ដោយក្រសួងរ៉ែនិងថាមពល។

អនុក្រឹត្យនេះ មានសុពលភាពអនុវត្តលើបរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញានីមួយៗក្នុងរយៈពេល ១២ (ដប់ពីរ) ខែ បន្ទាប់ពីប្រកាសស្តីពីការកំណត់បរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញានោះចូលជាធរមាន។ កាលបរិច្ឆេទពិតប្រាកដសម្រាប់ការអនុវត្តអនុក្រឹត្យនេះ និងប្រកាសពាក់ព័ន្ធ នឹងត្រូវជូនដំណឹងដោយក្រសួងរ៉ែនិងថាមពល ។

អនុក្រឹត្យនេះ មានសុពលភាពអនុវត្តក្នុងរយៈពេល ១២ (ដប់ពីរ) ខែ ក្រោយពេលប្រកាសស្តីពីការកំណត់បរិក្ខារប្រើប្រាស់អគ្គិសនីមុខសញ្ញាចូលជាធរមាន។

## ជំពូកទី១០
## អវសានប្បញ្ញត្តិ

**មាត្រា២៧ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២៨ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ សុក្រ ១០ កោច ខែ ទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**

**ស៊ុយ សែម**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ